# ព្រះលកុលីស (ភស្តុតាងផ្នែកប្រវត្តិសិល្បៈនៃនិកាយបាសុបតក្នុងសង្គមខ្មែរ)

បាសុបត ជាឈ្មោះនិកាយចំណាស់បំផុតក្នុងចំណោមនិកាយទាំងបួនក្នុងលទ្ធិសៃវនិយម នៃព្រហ្មញ្ញសាសនា រួមមាន បាសុបត, សៃវ (សៃវ-សិទ្ធានត្តិក), កាលវទ (កាលមុខ), និងនិកាយកាបាលិក)។ យ៉ាងហោចណាស់ មានសិលាចារឹកចំនួនពីរផ្ទាំងនៅស.វ.ទី៧ ដែលបង្ហាញអំពីការប្រតិបត្តិនិកាយបាសុបតនៅក្នុងសង្គមខ្មែរ ដោយមួយផ្ទាំងរកឃើញនៅសំបូរព្រៃគុក K.604 និងមួយផ្ទាំងទៀតរកឃើញនៅភ្នំព្រះវិហារ ខេត្តកំពង់ឆ្នាំង K.733។ ទោះបីជាមានភស្តុតាងសិលាចារឹកយ៉ាងនេះក្តី លោក Battacharya ស្នើថា ភស្តុតាងទាំងនេះនៅតែមានភាពខ្វះចន្លោះនៅឡើយ ហើយដើម្បីបំពេញចន្លោះប្រហោងនេះបាន លុះត្រាតែមានការរកឃើញសិលាចារឹកថ្មីបន្ថែម ឬទាល់តែមានការរកឃើញចម្លាក់ព្រះលកុលីសនៅតាមសំណង់ព្រហ្មញ្ញសាសនាខ្មែរ។ ហេតុដូច្នេះហើយ អត្ថបទនេះនឹងបង្ហាញឱ្យឃើញថា ចម្លាក់ព្រះលកុលីសបានលេចឡើងនៅតាមចម្លាក់ខ្មែរតាំងពីស.វ.ទី៧មកម៉្លេះ ពោល គឺបង្ហាញនៅលើផ្តែរទ្វារមួយដែលរកឃើញនៅក្រុមប្រាសាទតោ (ប្រាង្គ C6-03) នៃតំបន់ប្រាសាទសំបូរព្រៃគុក។ តើព្រះលកុលីសជានរណា និងលេចឡើងបែបណាខ្លះនៅក្នុងសិល្បៈខ្មែរ?

ព្រះលកុលីស គឺជាឈ្មោះព្រះឥសូរនៅក្នុងជាតិទី២៨ ដែលបានក្លាយជាទេពដ៏សំខាន់ជាងគេនៅក្នុងនិកាយបាសុបត។ ឈ្មោះ "**លកុលីស**" លេចឡើងដំបូងគេនៅក្នុងគម្ពីរវាយុបុរាណ ត្រង់ជំពូកទី២៣ ដែលរៀបរាប់ថា *"ព្រះសិវបានប្រកាសប្រាប់ព្រះព្រហ្មថា នៅក្នុងជាតិទី២៨ ព្រះវិស្ណុនឹងកើតជាវាសុទេវ ហើយទ្រង់នឹងកើតទៅជាព្រាហ្មណ៍ម្នាក់នៅក្នុងក្រុងកាយោហន ដែលមានឈ្មោះថា **នាកុលីន** ឬ **លកុលីស**"*។ តាមគម្ពីរជាច្រើនបានបញ្ជាក់ថា ព្រះលកុលីស មានសិស្សជំនិតចំនួន ៤ នាក់ រួមមាន កុសិក, គគ៌្យ, មិត្រក និងរុស្ត។ ជាទូទៅ គេបង្ហាញទ្រង់ជាទេពកាន់ដំបង ព្រោះពាក្យថា "**លកុលីស**" ក្លាយមកពីពាក្យថា "**លាគុទិ**" ដែលប្រែថា "**អ្នកកាន់ដំបង**"។ អ្នកប្រាជ្ញជាច្រើន សន្និដ្ឋានថា ព្រះលកុលីស គឺជាតួអង្គម្នាក់ដូចព្រះពុទ្ធដែរ និងជាវីរបុរសដ៏អស្ចារ្យ ដែលដើរតួនាទីជាព្រះគ្រូម្នាក់ដែលមានដំបងនៅក្នុងដៃ ហើយជាអ្នកផ្សព្វផ្សាយលទ្ធិសៃវទៅកាន់សត្វលោក។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

តាមការសិក្សាស្រាវជ្រាវកន្លងមក ឥតមានឯកសារណាមួយដែលបានបង្ហាញអំពីចម្លាក់ព្រះលកុលីសនៅតាមប្រាសាទខ្មែរឡើយ ហើយសូម្បីតែនៅចម្លាក់នៅអាស៊ីអាគ្នេយ៍ទាំងមូលក៏មិនមានរកឃើញដែរ។ ប៉ុន្តែ ចម្លាក់ទេពមួយអង្គដែលឆ្លាក់នៅលើផ្តែរទ្វារប្រាសាទ C6-03 នៃតំបន់ប្រាសាទសំបូរព្រៃគុក ទំនងគួរឱ្យជឿជាក់បានថា គឺជាចម្លាក់ព្រះលកុលីសដំបូងគេបង្អស់នៅក្នុងសិល្បៈខ្មែរ។ ផ្តែរទ្វារនេះ រកឃើញដោយក្រុមអ្នកជំនាញនៃសាកលវិទ្យាល័យវ៉ាសេដា កាលពីឆ្នាំ ២០០៣ ដែលអាចចាត់ថ្នាក់បានថាជាសិល្បៈរចនាបថព្រៃក្មេង ក្នុងរវាងពាក់កណ្តាលស.វ.ទី៧ ពោល គឺអាចស្ថិតនៅចុងរជ្ជកាលព្រះបាទស្រីឦសានវរ្ម័នទី១ (គ.ស.៦១៦-៦៣៧) ឬរជ្ជកាលព្រះបាទស្រីភវវរ្ម័នទី២ (គ.ស.៦៣៧-៦៥៧)។ ចម្លាក់ទាំងមូលនៅលើផ្តែរទ្វារនេះបង្ហាញឱ្យឃើញអំពីកិច្ចពិធីសាសនាដ៏សំខាន់មួយ ដែលផ្នែកកណ្តាលនៃជួរខាងក្រោមបង្ហាញអំពីទេពមួយអង្គអង្គុយក្នុងកាយវិការមហារាជលីលសន *(mahārājalīlāsana)* ដោយមានព្រហស្តឆ្វេងកាន់ដំបងមួយដាក់សង្កត់ទៅលើស្មាឆ្វេង និងព្រះហស្តស្តាំដាក់ទម្លាក់ចុះក្រោម។ ទ្រង់ស្លៀកសំពត់ និងមានក្រណាត់ស្ពាយឆៀងស្មាខាងឆ្វេង ពាក់ខ្សែរកអង្កាំធំៗនៅលើក ពាក់ខ្សែដៃ និងពាក់មួកជំមួយគ្របកប់ស្ទឹកត្រចៀក។ រូបតួអង្គដែលមានកាន់ដំបងនេះហើយ ដែលយើងអាចកំណត់បានថាជាចម្លាក់ "**ព្រះលកុលីស**" ដំបូងគេនៅក្នុងសិល្បៈខ្មែរ។ នៅខាងស្តាំព្រះលកុលីសមានចម្លាក់ តួអង្គពីរនាក់កំពុងលើកដៃសំពះទៅកាន់ទ្រង់ រីឯនៅខាងឆ្វេងបង្អស់មានតួអង្គពីរនាក់ទៀតកំពុងលត់ជង្គង់ ដោយម្នាក់កាន់ក្អមទឹក និងម្នាក់ទៀតលើកដៃសំពះ។ តួអង្គទាំងបួននាក់នេះ យើងអាចកត់សម្គាល់ថាជាសិស្សជំនិតទាំងបួនរបស់ព្រះលកុលីស រួមមាន កុសិក, គគ៌្យ, មិត្រក និងរុស្ត (ឈ្មោះទាំងបួននេះយោងទៅតាមគម្ពីរលិង្គបុរាណ)។ បន្ថែមពីនេះ មានចម្លាក់តួអង្គម្នាក់ទៀតដែលអង្គុយក្នុងទម្រង់ជាមហារាជលីលសននៅខាងឆ្វេងជាប់នឹងតួអង្គព្រះលកុលីស ដោយព្រះហស្តស្តាំដាក់លើជង្គង់ស្តាំ និងព្រះហស្តឆ្វេងដាក់នៅលើកែងព្រះហស្តស្តាំ។ តួអង្គនេះស្លៀកពាក់ និងលម្អទៅដោយគ្រឿងអលង្ការជាច្រើនដូចតួអង្គព្រះលកុលីសដែរ។ ដូច្នេះ តួអង្គនេះយើងអាចកត់សម្គាល់ថា ទំនងជាព្រះមហេស្វរ (ឥសូរ) ដែលជាតួអង្គសំខាន់នៅក្នុងពិធីសាសនាដ៏ពិសេសមួយរបស់ព្រះ លកុលីស ដែលគេស្គាល់ថាពិធី "**បដ្ដពន្ធ**" *(Paṭṭabandha)* ដូចមានរៀបរាប់នៅក្នុងគម្ពីរ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

*គណាការិកា និងសរសេរដោយ រត្នដីកា។ ពិធីបដ្តពន្ធ ធ្វើឡើងជារៀងរាល់ខែចំថ្ងៃពេញបូណ៌មីនៃអស្វិន ដើម្បីរំដោះមនុស្សដែលមានអំពើបាបឱ្យទៅកើតឡើងវិញជាថ្មីនៅក្នុងជាតិមុខ ហើយពិធីនេះគេជឿថា នៅពេលដែលព្រះមហេស្វរពាក់ក្រណាត់ស្ពាយធៀង (**បដ្តពន្ធ** ប្រែថាក្រណាត់ស្ពាយធៀង) និងពោលពាក្យថា "**មហាត្ម្យ**" មនុស្សនឹងបានទៅកើតនៅស្ថានសួគ៌រាប់ពាន់ឆ្នាំដូចក្រណាត់សូត្រដែរ។ ម្ល៉ោះហើយ ក្រណាត់ស្ពាយធៀងដែលទេពទាំងពីរអង្គពាក់នៅលើស្មាខាងឆ្វេងគឺជាគ្រឿងដ៏ពិសិដ្ឋមួយនៅក្នុងពិធី "មហាត្ម្យ"។ គោលគំនិតនៃពិធីបដ្តពន្ធនេះ ហាក់ដូចជាមានភាពស៊ីសង្វាក់គ្នាជាមួយចម្លាក់រូបផ្កាដែលគេឆ្លាក់នៅលើក្បាច់មេដាយ៉ុង (ផ្នែកខាងលើនៃផ្តែរ) ជាពិសេសចម្លាក់ផ្កានៅក្នុងមេដាយ៉ុងខាងឆ្វេងដែលមានសញ្ញាសម្គាល់នៅលើកំពូល ដែលអាចជានិម្មិតសញ្ញានៃការចាប់ជាតិជាថ្មី។ ចំណុចនេះ វាស្របគ្នាទៅនឹងទ្រឹស្តីនៃសាសនាហិណ្ឌូដែលគេជឿថា ផ្កា គឺជាគ្រឿងដ៏ពិសិដ្ឋមួយតំណាងឱ្យភោគផល ទ្រព្យសម្បត្តិ ភាពរុងរឿង និងការចាប់កំណើតជាថ្មី។ ឧទាហរណ៍ ព្រះព្រហ្មកើតចេញពីផ្ចិតរបស់ព្រះវិស្ណុអង្គុយនៅលើផ្កាឈូក។*

*អ្វីដែលគួរកត់សម្គាល់ជាពិសេសនោះ ការបង្ហាញចម្លាក់ព្រះលកុលីស និងសិស្សជំនិតទាំងបួននៅលើផ្តែរទ្វារស.វ.ទី៧ ដែលរកឃើញនៅតំបន់ប្រាសាទសំបូរព្រៃគុកនេះ គឺស្របទៅនឹងទំនៀមនៃការប្រតិបត្តិនិកាយបាសុបតនៅក្នុងប្រទេសឥណ្ឌា។ នៅមុនស.វ.ទី៦ ក្នុងសិល្បៈឥណ្ឌាគេមិនដែលឆ្លាក់ព្រះលកុលីសក្នុងទម្រង់ជាមនុស្សកាន់ដំបងឡើយ រីឯចម្លាក់ព្រះលកុលីស និងសិស្សជំនិតទាំងបួន ទើបតែលេចឡើងនៅរវាងពាក់កណ្តាលស.វ.ទី៦ប៉ុណ្ណោះ ដូចដែលឃើញមាននៅលើហោជាងរូងភ្នំយោគេស្វរី និងបន្តមាននៅតាមប្រាសាទឥណ្ឌាជាច្រើនចាប់ពីស.វ.ទី៧ដល់ស.វ.ទី១០។ គួរចាប់អារម្មណ៍នោះ ចម្លាក់ព្រះលកុលីសនៅស្រុកឥណ្ឌាគេឆ្លាក់មានពីរទម្រង់ គឺការបង្ហាះអាក្រាតកាយ (បង្ហាញឱ្យពីលិង្គ) និងមិនអាក្រាតកាយ ហើយក្នុងចំណោមទាំងពីរទម្រង់នេះ លោក* Choubey *លើកឡើងថា ទម្រង់មិនអាក្រាតកាយគ្រាន់ជាការបន្ទាប់បន្សំតិចតួចប៉ុណ្ណោះ។ ផ្ទុយពីនៅស្រុកខ្មែរ ចម្លាក់ព្រះលកុលីស និងចម្លាក់ទេពផ្សេងៗទៀត គេមិនដែលបង្ហាញក្នុងទម្រង់អាក្រាតកាយ ឬបង្ហាញកេរ្តិ៍ខ្មាសឡើយ លើកលែងតែការឆ្លាក់ព្រះសិវលិង្គ។*

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*

ចំណុចចាប់អារម្មណ៍មួយទៀត ក្នុងសិល្បៈឥណ្ឌា គេមិនដែលប្រទះឃើញចម្លាក់ព្រះលកុលីសបង្ហាញនៅក្នុងពិធីបដ្ដពន្ធនោះឡើយ។

ជារួមមក ការរកឃើញចម្លាក់ព្រះលកុលីស នៅតំបន់ប្រាសាទសំបូរព្រៃគុក ដែលឆ្លាក់តាំងពីរវាងពាក់កណ្ដាលស.វ.ទី៧ ដូចបានរៀបរាប់ខាងលើ គឺជាទិន្នន័យផ្នែកប្រវត្តិសិល្បៈដ៏សំខាន់មួយ ដែលអាចបំពេញបន្ថែមកាន់តែច្បាស់ទៅលើព័ត៌មានដែលទទួលបានពីសិលាចារឹកអំពីការសាយភាយ និងការគោរពប្រណិប័តន៍និកាយបាសុបតនៅក្នុងសង្គមខ្មែរនាស.វ.ទី៧។ គួរចាប់អារម្មណ៍នោះ យើងអាចសន្និដ្ឋានថា ថ្វីត្បិតតែស្រុកខ្មែរទទួលឥទ្ធិពលនៃការគោរពប្រតិបត្តិនិកាយបាសុបតពីស្រុកឥណ្ឌាក៏ពិតមែន ក៏សិល្បករខ្មែរមិនបានយកលំនាំនៃការឆ្លាក់បង្ហាញព្រះលកុលីសដូចសិល្បៈឥណ្ឌាទាំងស្រុងនោះឡើយ។ ជាក់ស្ដែង ការបង្ហាញព្រះលកុលីសក្នុងពិធីបដ្ដពន្ធ ដែលគេមិនដែលប្រទះឃើញនៅស្រុកឥណ្ឌា បែរជាមានបង្ហាញនៅស្រុកខ្មែរតាំងពីស.វ.ទី៧ ទៅវិញ។ នេះសបញ្ជាក់ឱ្យឃើញថា ព្រាហ្មណ៍បាសុបត និងអ្នកចម្លាក់ខ្មែរ គឺបង្ហាញអំពីអ្វីដែលជាសិល្បៈដោយឡែកក្នុងតំបន់ ខុសពីអ្វីដែលមាននៅស្រុកឥណ្ឌា។

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

## ឯកសារពិគ្រោះ


Bakker, H.T. 2019. ‘Origin and Spread of the Pāśupata Movement about Heracles, Lakulīśa and Symbols of Masuclinity’, in *Where Art and Text Meet, Studies in the Cultural History of India*, available online in https://www.jstor.org/stable/10.1163/j.ctv2gjwvf9.32

Bhandar, D.R. 1906-1907. *Archaeological Survey of India, Annual Report,* Delhi.

Bhattacharya, K. 1955. ‘La secte des Pāçupata dans l’ancient Cambodge’ *Journal Asiatique,* 243/4: 480-487.

Cecil, E.A. 2020. ‘Seeking the ‘Lord with a Club’: Encountering Lakulīśa in the Pāśupata Landscape’, in *Mapping the Pāśupata Landscape,* available online in https://www.jstor.org/stable/10.1163/j.ctv2gwz5m.10

Chemburkur, S. 2022. ‘Dancers, Musicians, Ascetics, and Priests: Performance-Based Saiva Worship and its Development in the Temple Cults of Angkor’, in Andrea Acri and Peter Sharrock (eds.), *The Creative South, Buddhist and Hindu Art in Mediaeval Maritime Asia*, pp.192-221, Volume 1.

Chemburkur, S. and Kapoor, S. 2018. ‘Pāśupata Sect in Ancient Cambodia and Champa: Art Historical Evidence’, in Vô Vân Thâng and Peter D. Sarrock (eds.), *Masterpiece of the Da Nang Museum of Cham Sculpture,* pp. 45-57, Bangkok: River Books.

Choubey, M.C. 1997. *Lakulīsa in Indian Art and Culture,* Delhi: Sharada Publishing House.

Coedès, G. 1937. *Inscription du Cambodge,* Tome I: Hanoi.

Coedès, G. 1952. *Inscription du Cambodge,* Tome IV: Hanoi.

Filliozat, V. 2001. 'Pāśupata Śaivism in Karnāṭaka and Cambodia', *Siksācakr* 4 (2001) 24-27.

Finot, L. 1928. ‘Nouvelle Inscriptions de Sambor’, *Bulletin de l’École française d’Extrême-Orient,* 28/1: 43-46.

Guy, J. 2018, ‘Shiva’s land: understanding the religious landscape of early Southeast Asia’, *Cultural and civilizational links between India and Southeast Asia*, pp. 253 – 274, edited by Shyam Saran.

Kapoor, S. 2019. ‘Iconography of Pashupata Ascetics in Cambodia’, *Orientations 50/1*: 122-131.

Roveda, V. 2005. *Image of the gods,* River Book: Bangkok.


អត្ថបទដោយ៖ ម៉ង់ រ៉ាលី

Thorn, T. 2011. *The inventory of the collection in the Kampong Thom Museum*, Phnom Penh.

Vickery, M. 1998. *Society, Economics and Politics in pre-Angkor Cambodia: The 7th-8th Centuries.* Tokyo: Centre for East Asian Cultural Studies for UNESCO.

Wolters, O.W. 1979. "Khmer 'Hinduism' in the Seventh Century," in R.B. Smith & W. Watson (eds) *Early South East Asia: Essays in Archaeology, History and Historical Geography*, New York & Kuala Lumpur: Oxford University Press, pp.427-442.

**Report sources**

Sambor Prei Kuk Conservation Project (SCP). 2006. *Sambor Prei Kuk Inventory of Movable Objects*, Waseda University, Japan and Ministry of the Culture and Fine Arts, Cambodia; Tokyo.



រូបលេខ១៖ ផ្តែរទ្វាររកឃើញនៅក្រុមប្រាសាទតោ ប្រាង្គ C6-03 នៃតំបន់ប្រាសាទសំបូរព្រៃគុក



រូបលេខ២៖ លម្អិតចម្លាក់តួអង្គសំខាន់នៅចំកណ្តាលផ្តែរ ដែលអាចកត់សម្គាល់ថាជាព្រះលកុលីស

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៣៖ លម្អិតចម្លាក់សិស្សជំនិតទាំងបួនរបស់ព្រះលកុលីស



រូបលេខ៤៖ លម្អិតចម្លាក់តួអង្គនៅខាងឆ្វេងព្រះលកុលីស ដែលអាចសន្និដ្ឋានថាជា ព្រះមហេស្វរ (ព្រះឥសូរ) នៅក្នុងពិធីដ៏សំខាន់មួយរបស់ព្រះលកុលីសឈ្មោះថា "បដ្តពន្ធ"

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៥៖ លម្អិតចម្លាក់ផ្កាឆ្លាក់នៅខាងក្នុងមេដាយ៉ុង ដែលមួយក្នុងចំណោមផ្កាទាំងបីមានសញ្ញាសម្គាល់រាង រង់ចូលក្នុងហាក់ដូចជានិម្មិតសញ្ញាសម្គាល់តំណាងការ ចាប់កំណើត ឬចាប់ជាតិជាថ្មី





រូបលេខ២៦៖ ចម្លាក់ព្រះលកុលីសនិងសិស្សជំនិតទាំងបួន ឆ្លាក់នៅលើហោជាងរូងភ្នំ Yogeśvarī ក្នុងតំបន់ Mumbai ប្រទេសឥណ្ឌា ពាក់កណ្ដាលស.វ.ទី៦ (Photo: Bakker 2019)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី